ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០១២

# សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ

នៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់ខ្លួន ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិបានបញ្ជាក់ពីការប្តេជ្ញាចិត្ត ក្នុងការផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់ដល់សាធារណជនទាក់ទងនឹងដំណើរវិវឌ្ឍន៍សំខាន់នៅក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤។

សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ យោងទៅលើបទប្បញ្ញត្តិនានានៃវិធាន ៥៦ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ វិធាននេះចែងថា ការផ្សព្វផ្សាយជាសាធារណៈ នូវព័ត៌មានទាក់ទងនឹងសំណុំរឿងត្រូវតែមានការឯកភាពរួមគ្នាពីសហចៅក្រមស៊ើបអង្កេត។ ក្នុងករណីនេះ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិមានការសោកស្តាយណាស់ដែលថា សហចៅក្រមស៊ើបអង្កេតជាតិមិនឯកភាពឲ្យមានការផ្សព្វផ្សាយព័ត៌មាន ទាក់ទងនឹងសេចក្តីសម្រេចសំខាន់ៗដែលខ្លួនបានដាក់ជូននៅខែធ្នូ ទាក់ទងនឹងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ០២៣-២១៩-៨១៤ ទូរសារ (៨៥៥) ០២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh